**ជីវិតថ្មី នៅក្នុងព្រះគ្រីស្ទ** ដោយ អេលែន អ័តជីង

ជីវិតថ្មីដែលអ្នកមានជាមួយព្រះគ្រីស្ទ
គឺជាជីវិតដែលល្អប្រសើរបំផុតដែលអ្នកអាចមាន។ ព្រះយេស៊ូមានបន្ទូលថា «ខ្ញុំមក ដើម្បីឲ្យគេមានជីវិត ហើយឲ្យមានជីវិតពេញបរិបូរ។» (យ៉ូហាន ១០ ៖ ១០)។ ឥឡូវនេះយើងបានក្លាយជាកូនរបស់ព្រះហើយ (យ៉ូហាន ១៖ ១២)
វាជាការចាំបាច់ដែលអ្នកត្រូវរីកចម្រើននៅក្នុងទំនាក់ទំនងខាងព្រលឹងវិញ្ញាណរបស់អ្នកជាមួយនឹងព្រះជាម្ចាស់។ ការរីកចម្រើននេះ
គឺរីកចម្រើនតាមរបៀបជាច្រើន។

ក្នុងនាមជាកូន
គឺយើងមានតួនាទីនៅក្នុងការស្តាប់បង្គាប់ដល់ឪពុកនៅលើផែនដី
ហើយយើងក៏ត្រូវស្តាប់បង្គាប់ព្រះវរបិតាដែលគង់នៅស្ថានសួគ៌ដែរ
ដោយយើងតបស្នង
ដោយការអរព្រះគុណព្រះអង្គនូវអ្វីដែលទ្រង់បានធ្វើសម្រាប់យើង
ព្រមទាំងក្តីស្រឡាញ់របស់ព្រះអង្គសម្រាប់យើង។

ដោយការអានព្រះបន្ទូលព្រះអង្គ ដែលជាព្រះគម្ពីរ
យើងនឹងទទួលបាននូវការបង្ហាត់បង្រៀន ប្រដៅតម្រង់
សម្រាប់ការរស់នៅតាមផ្លូវដែលត្រឹមត្រូវ
និងស្គាល់ពីបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ សម្រាប់ជីវិតរបស់យើង (២ធីម៉ូថេ ៣៖ ១៦)។ ខ្ញុំសូមណែនាំឲ្យអ្នកអាន មួយជំពូកក្នុងមួយថ្ងៃ ឬ ផ្នែកនៃកណ្ឌគម្ពីរយ៉ូហាន នៅក្នុងព្រះគម្ពីរ។

ការអធិស្ឋានគឺជាការនិយាយទៅកាន់ព្រះ។
កុំគ្រាន់តែអធិស្ឋានពីកិច្ចការធំៗប៉ុណ្ណោះ
ប៉ុន្តែអ្នកក៏អាចអធិស្ឋានពីរឿងតូចតាចបានដែរ។
នៅក្នុងព្រះគម្ពីរបានចែងថា
យើងគួរតែអធិស្ឋានដោយការអរព្រះគុណជានិច្ច (ភីលីព ៤៖ ៦)

ការប្រាប់ដល់អ្នកផ្សេងទៀតពីព្រះគ្រីស្ទ
ប្រាប់ពីអ្វីដែលព្រះអង្គបានធ្វើសម្រាប់អ្នក
និងពីអត្ថន័យដ៏ជ្រាលជ្រៅដែលព្រះអង្គមានមកកាន់អ្នក (ម៉ាថាយ ២៨៖ ១៩, ២០)។

វាជាការចាំបាច់ដែលអ្នកត្រូវមានការប្រកបជាមួយនឹងអ្នកជឿដទៃទៀត
ដែលស្រឡាញ់ព្រះអង្គដែរ។ ដូចជារងើកធ្យូង ឬអុស ដែលវានឹងរលត់ទៅ
នៅពេលដែល ដកចេញពីភ្នក់ភ្លើង ដូចគ្នាដែរ យើងអាចនឹងត្រជាក់
នៅក្នុងសេចក្តីស្រឡាញ់ដែលយើងមានសម្រាប់ព្រះអង្គ
ប្រសិនជាយើងមិនប្រកបជាមួយនឹងអ្នកជឿផ្សេងទៀត។
ពួកគេក៏ជាផ្នែកនៅក្នុងការលើកទឹកចិត្តដល់យើងដែរ។

ជាចុងក្រោយ សូមនឹកចាំថាទោះជាសាតាំងព្យាយាមបំបាក់ទឹកចិត្ត
និងល្បួងអ្នក ព្រះយេស៊ូក៏បានជួបនូវការល្បួងដែរ (ម៉ាថាយ៤៖ ៤-១១)
ព្រមទាំងមានជ័យជំនះ!
ព្រះអង្គប្រទានកម្លាំងដល់យើងតាមរយៈអំណាចនៃព្រះវិញ្ញាណបរិសុទ្ធ។

សូមព្រះអង្គប្រទានពរអ្នកនៅក្នុងជីវិតថ្មីនេះ!

**រស់នៅអសកល្បជានិច្ច** ការសិក្សាផ្នែកទី១

១. តើមានអ្វីកើតឡើងនៅពេលដែលអ្នកជឿ (ទុកចិត្ត)
នៅក្នុងព្រះយេស៊ូគ្រីស្ទ (យ៉ូហាន ៥:២៤).

ជីវិតអសកល្បជានិច្ច
គឺមិនសម្រាប់តែជីវិតបន្ទាប់ពីស្លាប់ទៅហើយនោះទេ ប៉ុន្តែ
ជីវិតខាងព្រលឹងវិញ្ញាណយើង
ចាប់តាំងពីពេលដែលបុគ្គលម្នាក់បានជឿនៅក្នុងព្រះគ្រីស្ទ។
មិនមែនតាមរយៈការខំប្រឹងប្រែងធ្វើល្អ
ប៉ុន្តែតាមការជឿទុកចិត្តទៅលើព្រះយេស៊ូ និងការស្វែងរក
ដើម្បីដើរតាមផ្លូវរបស់ព្រះអង្គ។

សូមអាននៅក្នុង យ៉ូហាន៣៖ ១៦
ហើយបំពេញឈ្មោះរបស់អ្នកនៅក្នុងចន្លោះនីមួយៗ៖

«ដ្បិតព្រះទ្រង់ស្រឡាញ់.................................. ដល់ម្ល៉េះបានជាទ្រង់
ប្រទានព្រះរាជបុត្រាទ្រង់តែ១ ដើម្បីឲ្យ.................................. ដែលជឿ
ដល់ព្រះរាជបុត្រានោះ.......................... មិនត្រូវវិនាសឡើយ គឺឲ្យ........
..........................មានជីវិតអស់កល្បជានិច្ចវិញ។»

(អានសារឡើងវិញ)

២. តើអ្នកអាចច្បាស់ដែរឬទេ ដែលអ្នកនឹងមិនត្រូវវិនាសនោះ?
(យ៉ូហាន ១០៖ ២៧-២៨)

៣. តើព្រះយេស៊ូមានព្រះពន្ទូលសន្យាទៀតទេ ស្តីពីអនាគត ?
(យ៉ូហាន ១៤៖ ១-៣)

៤. តើព្រះយេស៊ូបានសន្យាយ៉ាងដូចម្តេចខ្លះ
ប្រសិនជាអ្នកស្តាប់បង្គាប់ព្រះអង្គ? (យ៉ូហាន ១៤៖ ២១)

សូមទន្ទេញខគម្ពីរចងចាំចំនួន៤ នៅចុងបញ្ចប់នៃកាសិក្សាផ្នែកទី២ ហើយបន្តអានព្រះគម្ពីរជាប្រចាំថ្ងៃ ទូលសូមព្រះអង្គសម្រាប់ជំនួយ និងការដឹកនាំសម្រាប់ថ្ងៃនីមួយៗ។
អ្នកអាចនឹងចង់បញ្ចេញគំនិតតាមរយៈការអានរបស់អ្នក ចេញពីគម្ពីរដំណឹងល្អយ៉ូហាន។

(បទគម្ពីរដកស្រង់ចេញពីព្រះគម្ពីរសម្រាយ ជាភាសាអង់គ្លេស)

**ការអត់ទោស** ការសិក្សាផ្នែកទី២

១. ហេតុអ្វីបានជាព្រះយេស៊ូយាងមកក្នុងលោកិយ? យ៉ូហាន១:២៩។

២. តើលោកពីឡាត់បាននិយាយអ្វីអំពីព្រះយេស៊ូ? យ៉ូហាន១៩:៦។

៣. ព្រះយេស៊ូបានទទួលរង ទារុណកម្មជំនួសយើង សម្រាប់អំពើរំលងរបស់យើង (អំពើបាប) តាមរយៈការសុគតរបស់ព្រះអង្គនៅលើឈើឆ្កាង។ មានន័យថា យើងមិនត្រូវបានទទួលរងទារុណកម្មទៀតទេ។ ទារុណកម្មនេះត្រូវបានដកចេញដោយសារសេចក្តីជំនឿ នៅក្នុងអ្វីដែលព្រះគ្រីស្ទ បានធ្វើ។ សូមអានអំពីការសុគតរបស់ព្រះអង្គ នៅក្នុង គម្ពីរយ៉ូហាន ១៩:១៧-៣០។

៤. នៅក្នុង ១យ៉ូហាន ១:៩ យើងអាន «បើយើងលន់តួបាបវិញ នោះទ្រង់មានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ប្រយោជន៍នឹងអត់ទោសបាបឲ្យយើង ហើយនិងសំអាតយើង ពីគ្រប់អំពើទុច្ចរិតទាំងអស់ផង»។ ដើម្បី «លន់តួបាប» មានន័យថា យើងសារភាពនៅចំពោះព្រះអង្គ ពីកំហុសដែលយើងបានធ្វើ។
បន្ទាប់ពីព្រះអង្គអត់ទោសយើងរួចហើយតើព្រះអង្គធ្វើអ្វីទៀត?

ម៉ាថាយ ៦:១៤-១៥ « ដ្បិតបើអ្នករាល់គ្នាអត់ទោសចំពោះការរំលងច្បាប់ដែលមនុស្សលោកប្រព្រឹត្តធ្វើ នោះព្រះវរបិតានៃអ្នក ដែលគង់នៅស្ថានសួគ៌ ទ្រង់នឹងអត់ទោសឲ្យអ្នករាល់គ្នាដែរ តែបើអ្នករាល់គ្នាមិនអត់ទោស ចំពោះការរំលងច្បាប់ឲ្យគេទេ នោះព្រះវរបិតានៃអ្នក ទ្រង់ក៏មិនអត់ទោស ចំពោះការរំលងច្បាប់ ដែលអ្នករាល់គ្នាប្រព្រឹត្តធ្វើដែរ។»

១. នៅក្នុងបទគម្ពីរនេះ តើយើងត្រូវធ្វើដូចម្តេចដើម្បីចេះអត់ទោស?
២.
តើធ្វើយ៉ាងណាទើបយើងអាចអត់ទោសដល់អ្នកដែលបានធ្វើខុសនឹងយើងបាន?

នៅពេលដែលអ្នកអាចដោះលែងអ្នកដទៃទៀត ពីការមិនអត់ទោសរបស់អ្នក នោះអ្នកក៏អាចទទួលបាននូវការអត់ទោសមកពីព្រះជាម្ចាស់ដែរ។ និយាយចេញពីការអត់ទោសរបស់អ្នកចំពោះអ្នកដែលបានធ្វើឲ្យអ្នកឈឺចាប់ និង បំបាក់ទឹកចិត្តរបស់អ្នក ហើយទទួល និងអរព្រះគុណព្រះអង្គសម្រាប់ការអត់ទោសដល់អ្នក។
មិនត្រូវភ្ញាក់ផ្អើលនោះឡើយ ប្រសិនជាអ្នកត្រូវធ្វើវាម្តងហើយម្តងទៀតនោះ។

រស់នៅជីវិតដើរជាមួយព្រះយេស៊ូ ជាព្រះសង្គ្រោះ ព្រះអម្ចាស់ និងមិត្តសម្លាញ់ ធ្វើឲ្យទំនាក់ទំនងរបស់អ្នកជាមួយព្រះអង្គកាន់តែស្និទ្ធស្នាល។
តែងតែមានអ្វីជាច្រើនទៀតដែលត្រូវរៀនបន្ថែមទៀត!

ខគម្ពីរដែលត្រូវរៀន

| | |
|---|---|
| ព្រះបន្ទូលសន្យា ស្តីពីជីវិត<br>(យ៉ូហាន ៣៖ ១៦)<br><br>«ដ្បិតព្រះស្រឡាញ់មនុស្សលោកជាខ្លាំង បានជាទ្រង់ប្រទានព្រះរាជបុត្រាតែមួយរបស់ព្រះអង្គ ដើម្បីឲ្យអ្នកណាដែលជឿដល់ព្រះរាជបុត្រានោះ មិនត្រូវវិនាសឡើយ គឺឲ្យមានជីវិតអស់កល្បជានិច្ចវិញ។» | ព្រះបន្ទូលសន្យា ស្តីពីជ័យជំនះលើការល្បួង (១កូរិនថូស ១០៖ ១៣)<br>«គ្មានសេចក្តីល្បួងណាកើតដល់អ្នករាល់គ្នា ក្រៅពីសេចក្តីល្បួងដែលមនុស្សលោកតែងជួបប្រទះនោះឡើយ។ ព្រះទ្រង់ស្មោះត្រង់ ទ្រង់មិនបណ្តោយឲ្យអ្នករាល់គ្នាត្រូវល្បួង ហួសកម្លាំងអ្នករាល់គ្នាឡើយ គឺនៅវេលាណាដែលត្រូវល្បួង នោះទ្រង់ក៏រៀបផ្លូវឲ្យចៀសរួច ដើម្បីឲ្យអ្នករាល់គ្នាអាចទ្រាំទ្របាន។» |
| ព្រះបន្ទូលសន្យា ស្តីពីការអត់ទោស<br>(១យ៉ូហាន ១៖ ៩)<br><br>«ប្រសិនបើយើងលន់តួបាបរបស់យើង នោះព្រះអង្គមានព្រះហឫទ័យស្មោះត្រង់ ហើយសុចរិត ព្រះអង្គនឹងអត់ទោសបាបឲ្យយើង ហើយសម្អាតយើងពីគ្រប់អំពើទុច្ចរិតទាំងអស់។ » | ព្រះបន្ទូលសន្យា<br>ស្តីពីព្រះវត្តមានទ្រង់ (ហេប្រឺ ១៣៖ ៥)<br><br>«យើងនឹងមិនចាកចេញពីអ្នក ក៏មិនបោះបង់ចោលអ្នកឡើយ» |

« ការរីកចម្រើន នៅក្នុងព្រះគ្រីស្ទ គឺជាការណែនាំដែលមាននៅក្នុងការសិក្សាទាំងនេះ។»